**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**
លេខ ០៩៤ ស.ជ.លា

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបែងចែកភាគលាភរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** (រ.ទ.ស.ភ) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ទាំងអស់ជ្រាបថា៖ រ.ទ.ស.ភ នឹងបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនធម្មតា ដូចខាងក្រោម៖

១- ប្រភេទភាគលាភដែលត្រូវបែងចែក(Type of Dividend): **សាច់ប្រាក់**

២- រយៈពេលភាគលាភ(Period of Dividend): **ប្រចាំឆ្នាំ២០១៤**

៣- អនុបាតនៃការបែងចែកភាគលាភ(Dividend Payout Ratio): **២០%**

៤- ភាគលាភសរុបដែលត្រូវបែងចែក(Total Dividend): **៩.១៤៩.៥៨២.២០០ រៀល**

៥- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(Dividend Per Share): **១០៥,២០ រៀល**

៦- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ(Record Date): **១៣ មេសា ២០១៥**

៧- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ(Payment Date): **២៤ មេសា ២០១៥**

**បញ្ជាក់** ៖

១- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការ ដែលទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកបណ្តោះអាសន្នរៀបចំឡើង នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥។

២- ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ នៅតែមានសិទ្ធិទទួលបាននូវភាគលាភដដែល។

៣- ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ នឹងមិនមានសិទ្ធិទទួលបានភាគលាភដូចបានកំណត់ខាងលើនោះទេ។

៤- ការទូទាត់ភាគលាភចាប់ផ្តើមពី ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ដល់ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ នៅរៀងរាល់ថ្ងៃធ្វើការ។ ក្នុងករណីមានភាពមិនត្រឹមត្រូវក្នុងការទូទាត់ភាគលាភខាងលើ ភាគហ៊ុនិកអាចធ្វើការតវ៉ា ចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ដល់ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ នៅរៀងរាល់ថ្ងៃធ្វើការ។



អាសយដ្ឋាន: លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទ: ៨៥៥ (២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh

ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ រ.ទ.ស.ក ដូចខាងក្រោម៖

- អាសយដ្ឋាន: អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ: (៨៥៥)២៣-៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ៨៣១៦៧)
- ទូរសារ: (៨៥៥)២៣-៩៩៨ ៦៦៦
- ទូរសព្ទដៃ: (៨៥៥)១៥ ៦០០ ៧៤៣
- អ៊ីម៉ែល: lim.an@acledabank.com.kh

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៥

•